**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

ជាន់ទី១២ អាគារ Exchange Square
ផ្លូវលេខ១០៦ កែងផ្លូវលេខ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្តីប្រកាសសារព័ត៌មាន

## អេ អាយ អេ ខេមបូឌា ផ្តល់ការការពារពិសេសដោយឥតគិតថ្លៃ លើករណីជំងឺកូវីដ១៩

**ភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០** – ថ្ងៃនេះ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") បានប្រកាសនូវការផ្តល់ជូនពិសេសដល់អតិថិជនទាំងចាស់ និងថ្មីទាំងអស់របស់ខ្លួន ទៅលើជំងឺកូវីដ១៩ ដោយឥតគិតថ្លៃ។ ការការពារបន្ថែមនេះ រួមមានការចំណាយសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ជាមួយនឹងថវិកាចំនួន ៥០០ដុល្លាអាមេរិកសម្រាប់អតិថិជនម្នាក់ ក្នុងករណីត្រូវបានពិនិត្យឃើញថាមានជំងឺកូវីដ១៩ និង ៥,០០០ដុល្លាអាមេរិកសម្រាប់អតិថិជនម្នាក់បន្ថែមទៀត ប្រសិនបើមានការបាត់បង់ជីវិតពីជំងឺនេះ។ ការផ្តល់ជូនពិសេសនេះ មានសុពលភាពពីថ្ងៃនេះរហូតដល់ថ្ងៃទី ៣០ មិថុនា ឆ្នាំ២០២០ បន្ថែមលើអត្ថប្រយោជន៍ធានារ៉ាប់រងដែលមានស្រាប់។

លោកស្រី Pauline Teoh អគ្គនាយិកាក្រុមហ៊ុន អេ អាយ អេ ខេមបូឌា បានមានប្រសាសន៍ថា «អេ អាយ អេ ខេមបូឌា នឹងនៅជាមួយប្រជាជនកម្ពុជា ដើម្បីរួមគ្នាប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩។ យើងប្តេជ្ញាផ្តល់ជូននូវភាពស្ងប់ចិត្តក្នុងគ្រាលំបាកនេះ តាមរយៈជំនួយហិរញ្ញវត្ថុបន្ថែមដល់ក្រុមគ្រួសារដែលទទួលរងផលប៉ះពាល់នេះ។»

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេនៅកម្ពុជា អេ អាយ អេ ខេមបូឌា មានជំហរយ៉ាងរឹងមាំទៅលើការប្តេជ្ញាចិត្តជួយឲ្យប្រជាជនកម្ពុជាទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ ហើយផ្តល់ជូនដល់ពលរដ្ឋគ្រប់រូបនូវការគាំទ្រដែលពួកគាត់ត្រូវការ ក្នុងពេលចាំបាច់នេះ។

សម្រាប់ព័ត៌មានលម្អិតបន្ថែម និងលក្ខខណ្ឌនៃការផ្តល់ជូនពិសេសនេះ សូមទាក់ទងទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care តាមរយៈលេខទូរស័ព្ទ ០៨៦ ៩៩៩ ៤២៤ ឬទាញយកព័ត៌មានថ្មីៗតាមរយៈគេហទំព័រ aia.com.kh។

**អំពី អេ អាយ អេ ខេមបូឌា**

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក ("អេ អាយ អេ ខេមបូឌា") គឺជាបុត្រសម្ព័ន្ធ និងជាកម្មសិទ្ធិទាំងស្រុងរបស់ AIA Group Limited ("AIA") ដែលជាសម្ព័ន្ធក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតធំជាងគេបំផុតនៅលើពិភពលោកដោយយោងតាមទីផ្សារមូលធននីយកម្ម។

សម្ព័ន្ធ AIA មានវត្តមាននៅក្នុងទីផ្សារចំនួន១៨នៅអាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះមានសាខា និងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិទាំងស្រុង នៅហុងកុង ថៃ សិង្ហបុរី ម៉ាឡេស៊ី ចិន កូរ៉េខាងត្បូង ហ្វីលីពីន អូស្ត្រាលី ឥណ្ឌូនេស៊ី តៃវ៉ាន់(ចិន) វៀតណាម ណូវែលហ្សេឡង់ ម៉ាកាវ ប្រ៊ុយណេ កម្ពុជា ភូមា ព្រមទាំងបុត្រសម្ព័ន្ធដែលជាកម្មសិទ្ធិ៩៩ភាគរយនៅសិរីលង្កា និងការវិនិយោគរួមគ្នា៤៩ភាគរយនៅឥណ្ឌា។

អាជីវកម្ម ដែលបានក្លាយទៅជា AIA បច្ចុប្បន្ននេះ បានចាប់ផ្តើមមួយសតវត្សកន្លងមក ក្នុងឆ្នាំ១៩១៩ នៅទីក្រុងសៀងហៃ។ AIA គឺជាក្រុមហ៊ុនឈានមុខគេនៅតំបន់អាស៊ីប៉ាស៊ីហ្វិក (លើកលែងជប៉ុន) ដោយយោងលើបុព្វលាភធានារ៉ាប់រងជីវិត និងឈានមុខគេនៅក្នុងទីផ្សារភាគច្រើនរបស់ខ្លួន។ AIA មានទ្រព្យសរុប២៨៤ពាន់លានដុល្លាអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ តាមរយៈបណ្តាញដ៏ទូលំទូលាយនៃភ្នាក់ងារ

ដៃគូ និងធនធានមនុស្សនានាទូទាំងអាស៊ីប៉ាស៊ីហ្វិក AIA បម្រើម្ចាស់បណ្ណសន្យាជានាវ៉ាប់រងច្រើនជាង៣៦លានបណ្ណ និងសមាជិកទទួលអត្ថប្រយោជន៍ធានារ៉ាប់រងតាមក្រុមហ៊ុននានាច្រើនជាង១៦លាននាក់។
អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយ និងសេវាកម្មធានារ៉ាប់រងអាយុជីវិតឈានមុខគេក្នុងទីផ្សារ ដើម្បីបំពេញតម្រូវការលើការការពារ និងការសន្សំរយៈពេលវែង របស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។ អេ អាយ អេ ខេមបូឌា ប្តេជ្ញាចូលរួមលើកកំពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាឲ្យបានយូរអង្វែង និងជួយឲ្យប្រជាជនខ្មែរទទួលបានសុខភាព និងជីវិតកាន់តែប្រសើរ។

**ទំនាក់ទំនងសារព័ត៌មាន**

ហាក់ បញ្ញារ័ត្ន
ប្រធានផ្នែកទីផ្សារ និងទំនាក់ទំនង
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
០១៦ ៣៦៩ ១៥៥
Panharath.Hak@aia.com